# កិច្ចតែងការបង្រៀន

- កាលបរិច្ឆេទ ៖ ថ្ងៃ ចន្ទ ទី ០២ខែ មិថុនា ឆ្នាំ ២០២៥

- មុខវិជ្ជា ៖ ភាសាខ្មែរ

- ប្រធានបទ ៖ ប្រើពាក្យសម្ដីកាយវិការ និងនិមិត្តសញ្ញាដើម្បីទំនាក់ទំនង

- សកម្មភាពគោល ៖ រឿងនិទាន

- ចំណងជើង ៖ ចិត្រាចូលចិត្តញ៉ាំបន្លែ

- កម្រិតថ្នាក់ ៖ មធ្យម

- រយៈពេល ៖ ៣០នាទី

## I. វត្ថុបំណងមេរៀន

- វិជ្ជាសម្បទា៖ កុមារប្រាប់បានពីចំណងជើងរឿង ឈ្មោះអ្នកនិពន្ធ ពាក្យពិបាក និងអត្ថន័យបានត្រឹមត្រូវ តាមរយៈការស្ដាប់រឿងនិទាន។

- បំណិនសម្បទា៖ កុមារកំណត់បានពី ចំណងជើង ឈ្មោះអ្នកនិពន្ធ ពាក្យពិបាក អត្ថន័យ និងអាចនិទានរឿងតាមរូបភាពឲ្យអ្នកដទៃស្ដាប់បានត្រឹមត្រូវ តាមរយៈការស្ដាប់រឿងនិទាន។

- ចរិយាសម្បទា៖ បណ្ដុះស្មារតីកុមារឲ្យមានទម្លាប់ល្អក្នុងការប្រើពាក្យសម្ដីទំនាក់ទំនងទៅវិញទៅមក និងមានឥរិយាបទល្អ ។

## II. សម្ភារៈឧបទេស

*ចំពោះគ្រូ ៖ បន្ទះរូបភាព

* ចំពោះសិស្ស៖ គ្មាន

* ការរៀបចំ និងទីកន្លែង៖ កុមារអង្គុយជាកន្លះរង្វង់(U)

* គោលវិធី៖ សិស្សមជ្ឈមណ្ឌល

## III. ដំណើរការបង្រៀន(កិច្ចតែងការ១ម៉ោងសិក្សា)

| IV. សកម្មភាពគ្រូ | ខ្លឹមសារបង្រៀន | សកម្មភាពសិស្ស |
|---|---|---|
| | ជំហានទី១ | |
| -តើកូនៗមកជុំគ្នាហើយឬនៅ?<br>ឲ្យមេក្រុមពិនិត្យសមាជិកក្នុងក្រុម<br>-តើកូនបានសម្អាតដៃឬនៅ?<br>-តើមានសម្លៀកបំពាក់ស្អាតឬនៅ? | +លំនឹងថ្នាក់<br>-ពិនិត្យវត្តមាន<br>-ពង្រឹងវិន័យ អនាម័យ<br>-សណ្ដាប់ធ្នាប់ | -មេក្រុមពិនិត្យសមាជិកក្នុងក្រុម<br>ហើយរាយការណ៍<br>-បង្ហាញដៃដែលលាងសម្អាតរួច<br>-សម្លៀកបំពាក់ស្អាតហើយ |

| | | |
|---|---|---|
| - កូនៗច្រៀងបទចម្រៀង "មកទីនេះ" | -ប្រមូលអារម្មណ៍ | -ច្រៀង |
| ជំហានទី២ | | |
| -តើថ្ងៃមុនអ្នកគ្រូបានបង្រៀនមុខវិជ្ជាភាសាខ្មែរអំពីអ្វី?<br><br>-តើកូនធ្លាប់ស្តាប់រឿងនិទានអ្វីខ្លះកូន?<br>-តើកូនណាខ្លះចូលចិត្តញ៉ាំបន្លែរាល់ថ្ងៃ? | +រំលឹកមេរៀនចាស់<br>-ភាសាខ្មែរ៖ រឿងនិទាន អត្ថប្រយោជន៍និងគ្រោះថ្នាក់<br><br>+ទំនាក់ទំនងមេរៀនថ្មី<br>-រៀបរាប់<br>-ត្រូវញ៉ាំបន្លែរាល់ថ្ងៃ | -រៀបរាប់<br><br>-រៀបរាប់<br>-ធ្លាប់/មិនធ្លាប់ |
| ជំហានទី៣(មេរៀនប្រចាំថ្ងៃ) | | |
| -ថ្ងៃនេះអ្នកគ្រូមានរឿងថ្មី កូនសាកទាយមើលថាជារឿងអ្វី?<br>-កូនថាតាមអ្នកគ្រូទាំងអស់គ្នា<br><br>-រឿងនេះនិពន្ធដោយអង្គការ វីម៉កកង់បីណាកូន<br>-ពន្យល់ពាក្យពិបាក<br><br><br><br><br><br><br>-និទានរឿងឲ្យកុមារស្តាប់ដោយលើកដាក់សម្លេង កាយវិការ ទឹកមុខទៅតាមតួអង្គ<br>-ពន្យល់អត្ថន័យនៃសាច់រឿងៈរឿងនេះគឺគេចង់ឲ្យកូនៗត្រូវចូលចិត្តញ៉ាំបន្លែជារៀងរាល់ថ្ងៃដើម្បីឲ្យយើងមានសុខភាព | មេរៀនថ្មី៖ភាសាខ្មែរ៖រឿងនិទានៈចិត្រាចូលចិត្តញ៉ាំបន្លែ<br>-កុមារទាយចំណងជើង<br><br>-ភាសាខ្មែរ៖រឿងនិទានៈចិត្រាចូលចិត្តញ៉ាំបន្លែ<br>-និពន្ធដោយអង្គការ វីម៉កកង់បី<br><br>-ពាក្យពិបាក៖<br>.ពាក្យ ឧស្សាហ៍ មានន័យថា ដែលមិនខ្ជិលច្រអូសលើការងារ<br>.ពាក្យ ប្រាជ្ញា មានន័យថា ការយល់ជាក់ច្បាស់ លើអ្វីមួយដោយប្រាកដច្បាស់លាស់<br>.ពាក្យ អត្ថប្រយោជន៍ មានន័យថា អ្វីៗដែលមានប្រយោជន៍សម្រាប់យើង<br>-និទានរឿង<br><br><br>-ពន្យល់អត្ថន័យនៃសាច់រឿងៈរឿងនេះគឺគេចង់ឲ្យកូនៗត្រូវចូលចិត្តញ៉ាំបន្លែជារៀងរាល់ថ្ងៃដើម្បីឲ្យយើងមានសុខភាព | -ទាយចំណងជើង<br><br>-ស្តាប់ថាតាម<br><br>-ស្តាប់<br><br>-ស្តាប់<br><br><br><br><br><br><br>-ស្តាប់<br><br><br>-ស្តាប់ |

| | | |
|---|---|---|
| ល្អ និងរាងកាយមាំមួន គ្មានជំងឺ និងរៀនពូកែ<br>-សង្ខេបរឿងឲ្យកុមារស្តាប់<br>-កូនណាក្លាហានអាចឡើងមកនិទានរឿងឲ្យមិត្តភក្តិស្តាប់ម្តងទៀតបាន? | ល្អ និងរាងកាយមាំមួន គ្មានជំងឺ និងរៀនពូកែ<br>-សង្ខេបរឿង<br>-ឲ្យកុមារនិទានរឿងឡើងវិញ១ឬ២នាក់ | -ស្តាប់<br>-កុមារឡើងនិទានរឿង |
| ជំហានទី៤ | | |
| -អម្បាញ់មិញកូនរៀនអំពីអ្វី?<br>-តើនៅក្នុងរឿងនេះមានបន្លែអ្វីខ្លះកូន? | +ពង្រឹងចំណេះដឹង<br>-ភាសាខ្មែរ៖រឿងនិទានៈ ចិត្រាចូលចិត្តញ៉ាំបន្លែ<br>-ត្រកួន ស្ពៃ សាឡាដ ននោង ត្រឡាចល្ពៅ ប៉េងប៉ោះ...... | -ឆ្លើយ<br>-រៀបរាប់ |
| ជំហានទី៥ | | |
| - ថ្ងៃនេះអ្នកគ្រូសប្បាយចិត្តណាស់ដោយឃើញកូនៗមានភាពវៃឆ្លាត និងយកចិត្តទុកដាក់ក្នុងពេលរៀន<br>- ពេលត្រឡប់ទៅផ្ទះវិញ កូនកុំភ្លេចជម្រាបឪពុកម្តាយកូនថាកូនបានរៀនភាសាខ្មែរ៖រឿងនិទានៈ ចិត្រាចូលចិត្តញ៉ាំបន្លែ និង ត្រូវញ៉ាំបន្លែ ផ្លែឈើ ដែលម៉ាក់ប៉ាចំអិននៅផ្ទះជារៀងរាល់ថ្ងៃផងណាកូន | +បណ្តាំផ្ញើ និងលើកសរសើរ<br>-លើកទឹកចិត្ត និងសរសើរ<br>-បណ្តាំផ្ញើ | - ស្តាប់ដោយសប្បាយរីករាយ<br>-ស្តាប់ដោយយកចិត្តទុកដាក់ |

<u>*មតិយោបល់*</u>……………………………….

…………………………………………….

……………………………………………..

…………………………………………….

ថ្ងៃចន្ទ ទី០២ ខែ មិថុនាឆ្នាំ ២០២៥

គ្រូប្រចាំថ្នាក់

ឈាន សុមឿន

បានពិនិត្យត្រឹមត្រូវ

ថ្ងៃទី………ខែ…………..ឆ្នាំ ២០...

នាយិកាសាលា